ភ្នំពេញ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# កិច្ចប្រជុំពិភាក្សាលើការងារប្រមូលពន្ធប្រថាប់ត្រា នៅរដ្ឋបាលរាជធានីភ្នំពេញ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ០៨:០០ នាទីព្រឹក ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៧ នៅសាលារាជធានីភ្នំពេញ មានរៀបចំកិច្ចប្រជុំពិភាក្សាការងារប្រមូល ពន្ធប្រថាប់ត្រា នៅរដ្ឋបាលរាជធានីភ្នំពេញ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ, ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនិងវត្តមានចូលរួមរបស់អភិបាលនៃគណៈអភិបាលខណ្ឌទាំង១២នៃរាជធានី ប្រធាន-អនុប្រធាន នាយកដ្ឋានថ្នាក់កណ្តាលនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធានមន្ទីរជំនាញក្រោមឱវាទសាលារាជធានី ប្រធានសាខាពន្ធដារខណ្ឌ និងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ប៉ា សុជាតិវង្ស** បានសម្តែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានឯកឧត្តម លោក-លោកស្រី មន្ត្រីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ និង សម្តែងការកោតសរសើរចំពោះអគ្គនាយកដ្ឋានពន្ធដារ ដែលបានខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធ រហូតសម្រេចបានលទ្ធផលល្អប្រសើរជាពិសេស ការអនុវត្តគោលនយោបាយកែទម្រង់ តាមរយៈការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារក្នុង



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ការប្រមូលចំណូលប្រកបដោយ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ក្នុងបរិបទដែលរាជរដ្ឋាភិបាលមិនបង្កើតពន្ធថ្មី មិនដំឡើងអត្រាពន្ធ ប៉ុន្តែត្រូវប្រមូលពន្ធឱ្យបានអស់សក្តានុពលដែលមានស្រាប់។

ទន្ទឹមនឹងនេះឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ក៏ដូចជាលោកអភិបាលនៃគណៈអភិបាលខណ្ឌ បានលើកឡើងថា តាមរបាយការណ៍ និងការលើកឡើងរបស់អាជ្ញាធរមូលដ្ឋាន ក៏ដូចជាប្រជាពលរដ្ឋថា ការបង់ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ត្រូវប្រើរយៈពេលយូរ អាចរហូតដល់ទៅ ០៣ខែ និងថា តម្លៃ មូលដ្ឋានគិតពន្ធនៅតាមតំបន់មួយចំនួន គួរត្រូវបានកែលម្អ។

ពាក់ព័ន្ធនឹងការងារនេះ **ឯកឧត្តម គង់ វិបុល** បានបំភ្លឺជូនអង្គប្រជុំយ៉ាងដូច្នេះថា ផ្អែកតាមប្រកាសលេខ ១១៤៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ “រយៈពេលនៃការផ្តល់សេវាសាធារណៈចំពោះការបង់ពន្ធប្រថាប់ត្រា ត្រូវចំណាយពេលពី ០៤ ទៅ០៨ថ្ងៃ នៃថ្ងៃធ្វើការ រាប់ចាប់ពីការដាក់ឯកសារគ្រប់គ្រាន់ជូនរដ្ឋបាលសារពើពន្ធ”។ ដូច្នេះ ការលើកឡើងជារឿយៗថាចំណាយពេលរហូតដល់ទៅ០៣ខែនោះ គឺជាការលើកឡើងដោយមិនមានមូលដ្ឋានច្បាស់លាស់ និងមិនឆ្លុះបញ្ចាំងការពិតនោះទេ។ អគ្គនាយកដ្ឋានពន្ធដារទទួលស្គាល់ថាមានភាពយឺតយ៉ាវ ក្នុងការសម្រេចអនុញ្ញាតឱ្យបង់ពន្ធប្រថាប់ត្រាលើករណីមួយចំនួនតូច គឺអាចបណ្តាលមកពីម្ចាស់អចលនទ្រព្យ ឬអ្នករត់ការផ្តល់កិច្ចសហការនៅមានកម្រិត ដោយ ÷

- មិនបានផ្តល់ឯកសារគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ដើម្បីធ្វើជាមូលដ្ឋានវាយតម្លៃគិតពន្ធ

- មិនទាន់បង់ពន្ធលើអចលនទ្រព្យឬពន្ធលើដីធ្លីមិនប្រើប្រាស់ ឬមិនទាន់ដោះស្រាយបំណុលពន្ធដែលជាប់ពាក់ព័ន្ធ
- មិនឯកភាព ឬមិនទទួលយកការកំណត់ពន្ធដែលមន្ត្រីពន្ធដារធ្វើឡើងផ្អែកតាមតម្លៃ ដែលមានចែងក្នុងប្រកាសលេខ ៩៦២ សហវ.ប្រក ហើយនៅតែទាមទារតាមតម្លៃដែលពួកគាត់ចង់បង់ ដែលមានតម្លៃទាបជាងមូលដ្ឋានគិតពន្ធកំណត់ក្នុងប្រកាសនេះ
- មិនបានមកទទួលយកលិខិតជូនដំណឹងពីរដ្ឋបាលសារពើពន្ធ ទៅបង់ពន្ធបានទាន់ពេលវេលា
- អ្នករត់ការមួយចំនួន ទុកឯកសារចោលក្នុងរយៈពេលយូរ ដោយមិនបានបញ្ជូនឯកសារមករដ្ឋបាលសារពើពន្ធដើម្បីបន្តនីតិវិធីបង់ពន្ធប្រថាប់ត្រា ហើយឆ្លើយប្រាប់ម្ចាស់អចលនទ្រព្យថា ឯកសារនៅរដ្ឋបាលសារពើពន្ធ។

បន្ថែមពីលើនេះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានជម្រាបជូនអង្គប្រជុំថា អគ្គនាយកដ្ឋានពន្ធដារបានរៀបចំប្រព័ន្ធ IT សម្រាប់ការគ្រប់គ្រង ច្បាស់លាស់អំពីវិហ្វរឯកសារ ដោយមានចុះកាលបរិច្ឆេទនៃការទទួលឯកសារពីអ្នកជាប់ពន្ធ និងកាលបរិច្ឆេទនៃវិហ្វរឯកសារគ្រប់ដំណាក់កាល របស់មន្ត្រីទទួល បន្ទុកពាក់ព័ន្ធ ហើយប្រជាពលរដ្ឋអាចតាមដានឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រា របស់ខ្លួនថាតើដំណើការដល់ណា ហើយ ដោយគ្រាន់ តែថតឯកសារ និងលេខបាកូដ (Barcode) រួចបញ្ជូនមករដ្ឋបាលសារពើពន្ធតាមរយៈ **WhatsApp** ឬ **Telegram** ឬ **Line** ដែលមានលេខទូរស័ព្ទ**092031025** ឬអាចទំនាក់ទំនងតាម

រយៈទូរស័ព្ទលេខ (Hotline) 023 884 818 ឬអញ្ជើញមករដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកជាមួយនូវលិខិតដែលមានលេខសម្គាល់បាកូដ ដើម្បីទទួល បាននូវព័ត៌មានដែលពាក់ព័ន្ធនេះ។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានជម្រាបជូនអង្គប្រជុំបន្ថែមថា អគ្គនាយកដ្ឋានពន្ធដារនឹងខិតខំពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យបានកាន់តែឆាប់រហ័ស និងល្អប្រសើរ ព្រមជាមួយនោះ នឹងចាត់មន្ត្រីពន្ធដារបន្ថែម ទៀត ដើម្បីប្រចាំការនៅតាមការិយាល័យច្រកចេញ- ចូលតែមួយនៃសាលាខណ្ឌនីមួយៗ ដើម្បីសម្រួលដល់ការផ្តល់ សេវា និងជួយពន្យល់ណែនាំប្រជាពលរដ្ឋអំពីនីតិវិធីនៃការ បង់ពន្ធប្រថាប់ត្រាឱ្យកាន់តែយល់ច្បាស់ថែមទៀត។

ចំពោះការស្នើឱ្យមានការកែលម្អតម្លៃមូលដ្ឋានគិតពន្ធនៅតំបន់មួយចំនួន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានជម្រាបជូនថា អគ្គនាយកដ្ឋានពន្ធដារអនុវត្តស្របតាមប្រកាសលេខ ៩៦២ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ដែលតម្លៃមូលដ្ឋានគិតពន្ធនេះ ត្រូវបានរៀបចំដោយអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យរាជធានីភ្នំពេញ ហើយដែលអនុគណៈកម្មការនេះមានសមាសភាពចូលរួមពីគ្រប់ផ្នែកពាក់ព័ន្ធ និងពីអាជ្ញាធរដែនដី។ ជាងនេះទៅទៀត អគ្គនាយកដ្ឋានពន្ធដារក៏បានរៀបចំផែនទីកំណត់តម្លៃគិតពន្ធសម្រាប់ខណ្ឌនីមួយៗក្នុងរាជធានីភ្នំពេញ ផងដែរ។

ប្រកាស និងផែនទីទាំងនេះត្រូវបានផ្សព្វផ្សាយក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ និងមានបិទផ្សាយនៅតាមសាខាពន្ធដារខណ្ឌទាំងអស់ ព្រមទាំងបានផ្ញើជូនសាលារាជធានី ជាពិសេសសង្កាត់ទាំងអស់ក្នុងរាជធានីភ្នំពេញ។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ក៏បានស្នើឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី និងជាប្រធាននៃអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ រាជធានីភ្នំពេញ ពិនិត្យ និងសិក្សាឡើងវិញចំពោះតម្លៃមូលដ្ឋាន គិតពន្ធអចលនទ្រព្យ នៅតំបន់មួយចំនួនដែលមានការតវ៉ាពីសំណាក់ប្រជាពលរដ្ឋ ដើម្បីដាក់ជូនឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ និងសម្រេច។

ព្រមជាមួយនេះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍ ចាត់តំណាងអគ្គនាយកដ្ឋានពន្ធដារមួយរូបថ្នាក់អគ្គនាយករង ដើម្បីចូលរួមរាល់កិច្ចប្រជុំដែលរៀបចំដោយគណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ និងប្រធានសាខាពន្ធដារខណ្ឌ ដើម្បីចូលរួមរាល់កិច្ចប្រជុំដែលរៀបចំដោយគណៈបញ្ជាការឯកភាពខណ្ឌនីមួយៗ ក្នុងរាជធានីភ្នំពេញ។

បន្ទាប់ពីបានពិភាក្សាយ៉ាងផុសផុល អង្គប្រជុំបានយល់គ្នាអំពីមូលហេតុនៃការយឺតយ៉ាវក្នុងការផ្តល់សេវា ហើយឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី បានឯកភាពគ្នាក្នុងការពង្រឹងកិច្ចសហការគ្នា លើការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែមានគុណភាព សាមញ្ញ ស័ក្តិសិទ្ធិ គួរឱ្យទុកចិត្ត រហ័ស ងាយស្រួល សមស្របទៅនឹងសេចក្តីត្រូវការ និងមានការចូលរួមពីប្រជាពលរដ្ឋ ដោយតម្កល់ផលប្រយោជន៍ជាតិជាចម្បង៕


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ